**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩៤៨ អក
ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨
សាលក្រមព្រហ្មទណ្ឌលេខ៖ ៦១(៥៥)
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង ៣០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តកណ្ដាល

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

### មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

មេធាវី [redacted] ការពារសិទ្ធិឲ្យឈ្មោះ [redacted] យ៉ាវម៉ី

### មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវី [redacted] និង ការពារសិទ្ធិឲ្យឈ្មោះ [redacted] វិរាជ្យ និង ឈ្មោះ [redacted] ធឿន

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩៤៨ អក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] វិរាជ្យ ភេទប្រុស អាយុ៤៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើត [redacted] ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅភូមិស្លែងធំមុះ ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] តៀ "ស្លាប់" ម្ដាយឈ្មោះ ភើ "ស្លាប់" មានប្រពន្ធឈ្មោះ [redacted] ឡុង "រស់" មានកូន ០៣នាក់ ជាទីតិជន ទោសពីមុន៖ ធ្លាប់ជាប់ពន្ធនាគារខេត្តកណ្ដាល ១៣ថ្ងៃ ករណីរំលោភលើទំនុកចិត្ត។ (ក្រៅឃុំ)

២.ឈ្មោះ [redacted] ធឿន ភេទប្រុស អាយុ៣៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ នាយកសាលាបឋមសិក្សាព្រៃលគោ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្ដាល ទីលំនៅបច្ចុប្បន្ននៅ



Scanned with CamScanner



Scanned with CamScanner

ភូមិក្រោលគោ ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ទីម "ស្លាប់" ម្តាយឈ្មោះ [redacted] នាង "រស់" មានប្រពន្ធឈ្មោះ [redacted] ផាន "រស់" មានកូន ០៣ នាក់ ជានីតិជន ទោសពីមុន៖ ធ្លាប់ជាប់ពន្ធនាគារខេត្តកណ្តាល ១៣ថ្ងៃ ករណីរំលោភលើទំនុកចិត្ត ។(ក្រៅឃុំ)

ជាប់ចោទពីបទ៖ **ឆបោក** ប្រព្រឹត្តនៅភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីអំឡុងខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០១៨ តាមមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **យារមុំ** ភេទស្រី កើតឆ្នាំ១៩៧០ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៤៦៨ ផ្លូវវ៉ាដា ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភំពេញ។

សាក្សីឈ្មោះ [redacted] **ប៊ុនឡេង** ភេទប្រុស អាយុ ២៩ឆ្នាំ មុខរបររកស៊ី មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកក្រើស ឃុំព្រែកក្រើស ស្រុកកំពង់ត្រាច ខេត្តកំពត។

សាក្សីឈ្មោះ [redacted] **ស្រីណា** ភេទស្រី អាយុ ២៧ឆ្នាំ មុខរបរ នៅផ្ទះ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកក្រើស ឃុំព្រែកក្រើស ស្រុកកំពង់ត្រាច ខេត្តកំពត។

សាក្សីឈ្មោះ [redacted] **សារី** ហៅ **ធឿន** ភេទប្រុស អាយុ ៥៥ឆ្នាំ មុខរបរ អាជីវករ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៤៦៨ ផ្លូវវ៉ាដា ភូមិទំនប់ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] **យារមុំ**។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៖ **១១១៨ ដកសស** ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ **៩៧០ ដក.សព/២០** ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-**បានឃើញ** ដីកាដំណោះស្រាយលេខ៖ **១០១៥ ដកដស/២០** ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ។

## **ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

នៅអំឡុងខែមករា ឆ្នាំ២០១៨ ក្រោយដឹងថាជនរងគ្រោះឈ្មោះ [redacted] យារមុំ ភេទស្រី អាយុ៤៨ឆ្នាំ មានបំណងប្រមូលដីនៅចំណុចពាមតាសេកស្ថិតក្នុងភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ជនត្រូវចោទឈ្មោះ [redacted] វីរាជ្យ និងឈ្មោះ [redacted] ធឿន បានចូលទៅជួបជនរងគ្រោះដោយយកគំនូសបង្ហាញទីតាំងដីទំហំជាង៤០ហិកតាទៅបង្ហាញ និងអះអាងថាអាចប្រមូលទិញដីពីប្រជាពលរដ្ឋម្ចាស់ដីដើម្បីរៀបដីឲ្យជនរងគ្រោះបាន។ ក្រោយពីបានពិនិត្យប្លង់បង្ហាញទីតាំងរួចជនត្រូវចោទទាំងពីរនាក់បាននាំជនរងគ្រោះទៅមើលទីតាំងដីបន្ថែមទៀត។ បន្ទាប់មកជនរងគ្រោះ និងជនត្រូវចោទបានឯកភាពក្នុងការទិញលក់ក្នុងតម្លៃ ៤,៧(បួនក្បៀសប្រាំពីរ)ដុល្លារ ក្នុងមួយម៉ែត្រការ៉េ និងបានប្រគល់ប្រាក់ទៅជនត្រូវចោទបន្តបន្ទាប់ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០១៨ នូវចំនួនដូចមាននៅក្នុងកិច្ចសន្យាប្រគល់ប្រាក់កក់រវាងជនរងគ្រោះ និងជនត្រូវចោទ។ ក្រោយពីបានប្រគល់ប្រាក់រួចហើយ ជនរងគ្រោះព្យាយាមទំនាក់ទំនងទៅជនត្រូវចោទទាំងពីរដើម្បីសួរនាំពីដំណើរការវាស់វែងកំណត់ព្រំដី និងបែបបទផ្ទេរកម្មសិទ្ធិ ប៉ុន្តែជនត្រូវចោទព្យាយាមរកលេស

ពន្យាពេលរហូត ទើបនៅក្នុងខែឧសភា ឆ្នាំ២០១៨ ជនរងគ្រោះបានចុះទៅដល់ទីតាំងដី និងសាកសួរអាជ្ញាធរភូមិឃុំ និងប្រជាពលរដ្ឋម្ចាស់ដីក្នុងទីតាំងដីខាងលើក៏ដឹងថាជនសង្ស័យឈ្មោះ [redacted] វិរាជ្យ និងឈ្មោះ [redacted] ធឿន មិនបានយកប្រាក់ដែលជនរងគ្រោះប្រគល់ឱ្យទៅទិញដីពីប្រជាពលរដ្ឋនោះទេ។

## **នាពេលសួរចម្លើយ** 

១-ជនជាប់ចោទឈ្មោះ [redacted] វិរាជ្យ បានឆ្លើយថា៖ ចំពោះការទទួលប្រាក់ថ្លៃដីពីឈ្មោះ [redacted] យារម៉ី និងឈ្មោះ [redacted] សារី គឺមានខ្លួន និងឈ្មោះ [redacted] ធឿន ពេលបានប្រាក់ហើយខ្លួនប្រគល់បន្តឱ្យឈ្មោះ [redacted] ចាន់ថៃល និងឈ្មោះ [redacted] វុទ្ធា ដើម្បីយកទៅរៀបដីក្នុងឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល។ ចំពោះខ្លួន និងឈ្មោះ [redacted] ធឿន បានយកទៅកក់ឱ្យប្រជាពលរដ្ឋម្ចាស់ដី ប៉ុន្តែដោយមូលហេតុទម្លាក់ប្រាក់យឺតយ៉ាវរបស់ឈ្មោះ [redacted] យារម៉ី និងឈ្មោះ [redacted] សារី ទើបធ្វើឱ្យការកក់ប្រាក់ថ្លៃដីពីប្រជាពលរដ្ឋផុតកំណត់ ទើបដំណើរការរៀបចំដីមិនបានសម្រេច។

២-ជនជាប់ចោទឈ្មោះ [redacted] ធឿន បានឆ្លើយថា៖ នៅអំឡុងខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] សារី បានទាក់ទងមកខ្លួន និងឈ្មោះ [redacted] វិរាជ្យ ឱ្យទៅជួបគាត់នៅហាងកាហ្វេ។ ពេលទៅដល់បានឃើញឈ្មោះ [redacted] សារី និងប្រពន្ធឈ្មោះ [redacted] យារម៉ី និងក្មួយគាត់ឈ្មោះ [redacted] ប៊ុនលេង។ គាត់បានឱ្យខ្លួនរៀបចំដីប្រមាណ៤០ហិកតា នៅចំណុចពាមតាសេក ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល និងបានយកគំនូសប្លង់មួយផ្ទាំងធំ និងចង្អុលទីតាំងដែលគាត់ចង់បាន និងប្រាប់តម្លៃដែលគាត់ប៉ាន់ទិញ។ គាត់បានសួរថារៀបចំដីឱ្យគាត់បានទេ ពេលនោះខ្លួនមិនទាន់ឆ្លើយថាម៉េចទេដោយសុំពេលយកទៅសិក្សាសិន។ រំលងបាន ៣ថ្ងៃ ឈ្មោះ [redacted] សារី រួមជាមួយប្រពន្ធ បានទាក់ទងជាមួយឈ្មោះ [redacted] វិរាជ្យ និងខ្លួនជួបជាមួយគាត់នៅទីតាំងដីគាត់ចង់បាន និងមិនមានការប្រគល់ប្រាក់ទេ។ ក្រោយមកសិក្សារួចនៅអំឡុងខែកុម្ភៈ ឆ្នាំ២០១៨ ខ្លួន និងឈ្មោះ [redacted] វិរាជ្យ បានទៅជួបឈ្មោះ [redacted] សារី និងប្រពន្ធ បានប្រគល់ប្រាក់ចំនួន ៣ម៉ឺនដុល្លារ មកឱ្យខ្លួនធ្វើការ ដោយបានធ្វើឯកសារជាទម្រង់កិច្ចសន្យាទិញលក់ដីក្នុងខ្លឹមសារទទួលប្រាក់កក់ជាដំណាក់។ ក្រោយមកខ្លួនបានយកប្រាក់ទៅកក់ឱ្យប្រជាពលរដ្ឋម្ចាស់ដីតាមរយៈអ្នករៀបចំដីបន្តទៀត ឈ្មោះ [redacted] ចាន់ថៃល និងឈ្មោះ [redacted] វុទ្ធា ដែលជាអ្នកចុះទិញដីផ្ទាល់ពីប្រជាពលរដ្ឋ។ លុះដល់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨ ឈ្មោះ [redacted] សារី និងប្រពន្ធ បានទាក់ទងមកខ្លួនទៅជួបនៅផ្ទះ និងបានសួរនាំដំណើររៀបចំដីដល់ណាហើយ ខ្លួនឆ្លើយថា បាន១០%ហើយ ហើយបានប្រគល់ប្រាក់ ២ម៉ឺនដុល្លារបន្ថែមទៀត។ ខ្លួនក៏បានប្រគល់ប្រាក់ពីរម៉ឺនដុល្លារទៅឱ្យឈ្មោះ [redacted] ចាន់ថៃល និងឈ្មោះ [redacted] វុទ្ធា ធ្វើការបន្ត។ លុះដល់ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៨ ខ្លួនបានឱ្យគាត់ទម្លាក់លុយចំនួន ១៣ម៉ឺនដុល្លារ ថែមទៀត ដើម្បីយកទៅកក់ពីប្រជាពលរដ្ឋ ហើយគាត់បានយល់ព្រម។ ក្រោយមកនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៨ ពួកខ្លួនបានទាក់ទងទៅគាត់ថាជិតដល់ថ្ងៃទម្លាក់ប្រាក់ ១៣ម៉ឺនដុល្លារ ហើយរួចបានប្រគល់ប្រាក់ ១៨៥០០ដុល្លារ បន្ថែមទៀត និងដល់ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៨ ឈ្មោះ [redacted] សារី មិនបានទម្លាក់ប្រាក់ ១៣ម៉ឺនដុល្លារ មកពួកខ្លួនទេ។ ដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ ពួកខ្លួនបានយកប្រាក់ចំនួន ៤៨០០០ដុល្លារ ហើយខ្លួនបានថតចម្លងឯកសារដែលកក់ប្រាក់ពីប្រជាពលរដ្ឋជូនគាត់មើល

ហើយគាត់សន្យាថាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ គាត់នឹងបន្ថែមប្រាក់ ៣០% ទៅលើទំហំដាក់ស្តែង។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ គាត់បានឱ្យប្រាក់ ៣ម៉ឺនដុល្លារ និងសន្យាថាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ និងឱ្យប្រាក់ ៣ម៉ឺនដុល្លារទៀត ប៉ុន្តែគាត់មិនបានឱ្យទេ ជាហេតុធ្វើឱ្យដាច់ប្រាក់កក់ជាមួយប្រជាពលរដ្ឋជាច្រើននាក់។ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ឈ្មោះ [redacted] សារី បានឱ្យប្រាក់ចំនួន ៣២០០០ដុល្លារ ដើម្បីទិញរណ្តៅដី។ ចំពោះប្រាក់ដែលខ្លួនបានពីឈ្មោះ [redacted] សារី និងប្រពន្ធ សរុប១៨៨,៥០០ដុល្លារ។ ក្រោយមកឈ្មោះ [redacted] សារី និងប្រពន្ធមិនបានទាក់ទងពួកគាត់ទៀតទេ បែរជាធ្វើការជាមួយឈ្មោះ [redacted] ចាន់ថៃល និងឈ្មោះ [redacted] វុទ្ធា វិញ។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យាវម៉ី បានឆ្លើយថា៖ នៅអំឡុងដើមឆ្នាំ២០១៨ ឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ បានអះអាងថាពួកគេអាចរៀបចំដីឱ្យខ្លួនបាននូវទំហំ ៤០ ហិកតាជាង ចំណុចពាមតាសេកស្ថិតក្នុងភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ទើបខ្លួន និងប្តីឈ្មោះ [redacted] សារី រួមជាមួយឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ បាននាំគ្នាទៅមើលទីតាំងដី។ ក្រោយពីចុះដល់ទីតាំងដីតាមការចង្អុលបង្ហាញរបស់ឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ រំលងបានពីរអាទិត្យ អ្នកទាំងពីរបានជួបខ្លួននៅផ្ទះយកគំនូសប្លង់ទីតាំងមកបង្ហាញខ្លួន។ ក្នុងពេលនោះ អ្នកទាំងពីរបានអះអាងថាបានទំនាក់ទំនងទិញដីពីប្រជាពលរដ្ឋម្ចាស់ដីរួចរាល់ហើយ ប៉ុន្តែមិនបានដឹងពីចំនួនប្រជាពលរដ្ឋប៉ុន្មាននាក់នោះទេ ដោយជឿទុកចិត្តអ្នកទាំងពីរ ទើបខ្លួនយល់ព្រមទិញដីដែលពួកគេណែនាំ ក្នុងតម្លៃ ៤,៧ដុល្លារ ក្នុងមួយម៉ែត្រការ៉េ ហើយបានប្រគល់ប្រាក់ទៅអ្នកទាំងពីរជាបន្តបន្ទាប់សរុបចំនួន ១៨៩,៥០០(ដប់ប្រាំបីម៉ឺនប្រាំបួនពាន់ប្រាំរយ)ដុល្លារ។ ក្នុងពេលប្រគល់ប្រាក់ គឺធ្វើនៅផ្ទះខ្លួនគ្រប់ពេលដោយមានការចូលរួមពីឈ្មោះ [redacted] សារី, ឈ្មោះ [redacted] ប៊ុនលេង, ឈ្មោះ [redacted] ស្រីណា, ឈ្មោះ [redacted] វិរាជ្យ និងឈ្មោះ [redacted] ធឿន។ ក្រោយមកដល់ខែឧសភា មិនឃើញអ្នកទាំងពីររៀបចំផ្ទេរឈ្មោះឱ្យខ្លួន ហើយអ្នកទាំងពីរបានឆ្លើយដោះសារហូតទើបខ្លួនសង្ស័យបានចុះទៅដល់ទីតាំងដី និងទៅសាលាឃុំបានឃើញប្រជាពលរដ្ឋមកអះអាងប្រាប់ខ្លួន និងអាជ្ញាធរថា ឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ មិនបានយកប្រាក់មកកក់ថ្លៃដីទេគ្រាន់តែឱ្យប្រាក់ទ្រនាប់ដៃ ៥០ ទៅ ១០០ដុល្លារ ប៉ុណ្ណោះ។ ហើយចំពោះការទិញដីនេះ ខ្លួនមិនបានទាក់ទងជាមួយឈ្មោះ [redacted] ចាន់ថៃល និងឈ្មោះ [redacted] វុទ្ធា ដើម្បីរៀបចំដីបន្តពីឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យទេ។

៤-សាក្សីឈ្មោះ [redacted] ប៊ុនលេង ហៅ ប៊ុន បានឆ្លើយបំភ្លឺថា៖ នៅអំឡុងខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ បានមកជួបពូម៉ីងរបស់ខ្លួននៅផ្ទះ ដោយយកគំនូសទីតាំងមកបង្ហាញ។ ក្រោយពិនិត្យពូម៉ីងរបស់ខ្លួនបានប្រគល់ការងាររៀបចំដីឱ្យឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ។ បន្ទាប់មករំលងប្រហែល ៣ទៅ៤ថ្ងៃ ខ្លួនរួមទាំងពូម៉ីងបានទៅប្រាប់ពីទីតាំងដីដែលចង់បានឱ្យឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ រៀបអោយ។ ក្រោយពីដឹងទីតាំងរួច ប្រហែល ២ទៅ៣ថ្ងៃ ឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ បានមកជួបពូម៉ីងនៅផ្ទះ ដោយយកគំនូសទីតាំងមកជាមួយ។ គ្រានោះពូម៉ីងចរចារត្រូវគ្នាក្នុងតម្លៃ ៤,៧ដុល្លារ ក្នុងមួយម៉ែត្រការ៉េ។ ចំណែកខ្លួនបានធ្វើកិច្ចសន្យាលក់ទិញដីរវាងឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ





Scanned with CamScanner

ជាមួយមីងរបស់ខ្លួន និងបានប្រគល់លុយចំនួន ៣ ម៉ឺនដុល្លារ និងបន្តបន្ទាប់ទៀតជាច្រើនដង និងបានប្រគល់ប្រាក់សរុប ២០ម៉ឺនដុល្លារ។ លុះដល់ខែឧសភា យូរពេកពុំឃើញលទ្ធផល និងបានសួរទៅឈ្មោះ[redacted]ធឿន និងឈ្មោះ [redacted] វិរាជ្យ អ្នកទាំងពីរពន្យាពេលរហូត។ នៅពេលពូមីងខ្លួនបានចុះមកជួបមេឃុំ និងប្រជាពលរដ្ឋម្ចាស់ដីទើបដឹងថាមិនមានលក់ឱ្យឈ្មោះ[redacted]ធឿន និងឈ្មោះ[redacted]វិរាជ្យទេ ។

៥-សាក្សីឈ្មោះ [redacted]ស្រីណា បានឆ្លើយបំភ្លឺថា៖ ខ្លួនបានឃើញពូមីង បានប្រគល់ប្រាក់ថ្លៃដីទៅឈ្មោះ[redacted]ធឿន និងឈ្មោះ [redacted] វិរាជ្យ ប្រហែលពីរទៅបីដងនៅផ្ទះតែមិនដឹងចំនួនប៉ុន្មានដងទេ។ ចំណែកខ្លួននិងប្ដីឈ្មោះ [redacted] ប៊ុនលេង ក៏ធ្លាប់ប្រគល់ប្រាក់ជំនួសគាត់ចំនួន២ដងដែរ។ លើកទី១ ក្នុងឆ្នាំ២០១៨ ម៉ោងប្រហែល ១២ថ្ងៃ ពេលពូមីងមិននៅផ្ទះ ដើម្បីប្រគល់ឱ្យឈ្មោះ[redacted] ធឿន និងឈ្មោះ [redacted]វិរាជ្យ តែមិនចាំចំនួនលុយប៉ុន្មានទេ។ លើកទី២ ក្នុងឆ្នាំ២០១៨ ដដែល រំលងប្រហែលមួយខែ ម៉ោង ១២ថ្ងៃត្រង់ ពូមីងបានអោយខ្លួន និងប្ដីប្រគល់ប្រាក់ទៅឈ្មោះ [redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ ក្នុងចំនួនទឹកប្រាក់ ៣ម៉ឺនដុល្លារ ចំពោះការប្រគល់ប្រាក់នេះខ្លួន និងប្ដីបានថតរូបទុកដោយមានឈ្មោះ[redacted] ម៉េងលី ត្រូវជាប្អូនជាអ្នកថតឱ្យ។

៦-សាក្សីឈ្មោះ[redacted]សារី ហៅ ធឿន បានឆ្លើយបំភ្លឺថា៖ ខ្លួនបានស្គាល់ឈ្មោះ[redacted]ធឿន ជាង ១០ឆ្នាំមកហើយនិងខ្លួនបានប្រគល់ការងារទិញដីជាមួយឈ្មោះ[redacted] ធឿន និងឈ្មោះ [redacted] វិរាជ្យ ឱ្យទៅឈ្មោះ[redacted]យារ៉ុម៉ី ជាអ្នកឈរឈ្មោះ ព្រោះខ្លួនជាប់រវល់រៀបចំដីឱ្យចៅកែចិន នៅព្រះសីហនុ តែចំពោះការចុះទៅទីតាំងដី គឺខ្លួនជាអ្នកចុះផ្ទាល់។ អំឡុងខែមករា ឆ្នាំ២០១៨ ឈ្មោះ[redacted]ធឿន បានមកជួបខ្លួននៅផ្ទះដោយរៀបចំដីឱ្យខ្លួនទំហំ ៤០ ហិកតា នៅចំណុចឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល ពេលនោះខ្លួនបានយល់ព្រម និងបានប្រគល់ប្រាក់ចំនួន ៣ម៉ឺនដុល្លារ បន្ទាប់មករំលងមួយថ្ងៃខ្លួន និងឈ្មោះ [redacted]យារ៉ុម៉ី បានប្រាប់ពីទីតាំងដីដែលចង់បាន ហើយឈ្មោះ [redacted]ធឿន និងក្រុមការងារ និងមានឈ្មោះ[redacted]វិរាជ្យ ក៏ចូលរួមដែរ។ បន្ទាប់មក ៥ថ្ងៃ ឈ្មោះ[redacted]ធឿន និងឈ្មោះ[redacted]វិរាជ្យ បានមកផ្ទះខ្លួនយកគំនូសទីតាំងដីមានទំហំប្រហែល ៤០ហិកតា មកបង្ហាញ និងអះអាងថាបានទិញពីប្រជាពលរដ្ឋរួចរាល់ទើបខ្លួនប្រគល់ប្រាក់ចំនួន ១០ម៉ឺនបន្ថែមទៀត សរុបពីរលើក ១៣ម៉ឺនដុល្លារ។ បន្ទាប់មកឈ្មោះ[redacted] យារ៉ុម៉ី ជាអ្នកប្រគល់ប្រាក់ទៅឈ្មោះ[redacted]ធឿន និងឈ្មោះ [redacted]វិរាជ្យ ជាបន្តបន្ទាប់។ ចំពោះប្រាក់ប្រគល់ចំនួន ២០ម៉ឺនដុល្លារ ក្រោយមកទៀតខ្លួនបានឱ្យឈ្មោះ [redacted] ចំរើន ពិនិត្យមើលស្នាមមេដៃប្រជាពលរដ្ឋម្ចាស់ដីក្នុងឯកសារ ទើបដឹងថាប្រជាពលរដ្ឋទាំងនោះ មិនបានលក់ដីឱ្យឈ្មោះ[redacted]ធឿន និងឈ្មោះ [redacted] វិរាជ្យ គឺជាស្នាមមេដៃក្លែងក្លាយ។ ខ្លួនបានទាក់ទងទៅឈ្មោះ [redacted]ធឿន និងឈ្មោះ[redacted]វិរាជ្យ ឱ្យមកដោះស្រាយ តែអ្នកទាំងពីរមិនបានមកទេ។

៧-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋាន៖ ខ្លួនសូមរក្សាការទាមទារ និងសេចក្ដីថ្លែងការណ៍របស់កូនក្ដី ។

៨-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្រោយពីបានស្ដាប់ចម្លើយនាពេលសវនាការរួចមកឃើញថា ជនជាប់ចោទឈ្មោះ[redacted] វិរាជ្យ និងឈ្មោះ[redacted]ធឿន ពិតជាបានប្រព្រឹត្តអំពើ៖ ឆបោក ទៅ

នៅចំណុចភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល តាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន។

៣-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីការសួរដេញដោលរួចមកតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់លើជនជាប់ឈ្មោះ [redacted] **វិរាជ្យ** និងឈ្មោះ [redacted] **ធឿន** ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

៤-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន មានលក្ខណ:សមហេតុផលខ្លះ អាចឱ្យតុលាការទទួលយកមកពិចារណាបាន ។

៥-ជនជាប់ចោទឈ្មោះ [redacted] **វិរាជ្យ** និងឈ្មោះ [redacted] **ធឿន** មានចេតនាទុច្ចរិត ប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់ ដោយជនជាប់ចោទបានប្រព្រឹត្តអំពើបន្លំចំពោះរូបវន្តបុគ្គលដោយប្រើឧបាយកលទុច្ចរិតដែលនាំឱ្យខូចប្រយោជន៍របស់បុគ្គលដទៃនូវមូលនិធិ តម្លៃ ឬទ្រព្យសម្បត្តិអ្វីមួយ ដែលអំពើនេះ ចាត់ជាបទល្មើសព្រហ្មទណ្ឌពីបទ **ឆបោក** ត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៦-ជនជាប់ចោទ បានប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ ដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់ធ្នាប់សាធារណៈ និងសង្គម ព្រមទាំងប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ពលរដ្ឋដែលច្បាប់ការពារ។

៧-ជនជាប់ចោទ ជានីតិជន មានសមត្ថភាព និងលក្ខណ:សម្បត្តិគ្រប់គ្រាន់យល់ដឹងពីបច្ច័យ ដែលខ្លួនបានប្រព្រឹត្ត និងអាចទទួលខុសត្រូវព្រហ្មទណ្ឌចំពោះទង្វើរបស់ខ្លួន ដែលបានធ្វើសកម្មភាព ប៉ះពាល់សង្គម។

៨-មានធាតុផ្សំ នៃបទល្មើស និងភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] **វិរាជ្យ** ភេទប្រុស អាយុ៤៩ឆ្នាំ និងឈ្មោះ [redacted] **ធឿន** ភេទប្រុស អាយុ៣៧ឆ្នាំ ពីបទ **ឆបោក** ប្រព្រឹត្តនៅភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីអំឡុងខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០១៨ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

៩-តុលាការយល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] **វិរាជ្យ** ភេទប្រុស អាយុ៤៩ឆ្នាំ និងឈ្មោះ [redacted] **ធឿន** ភេទប្រុស អាយុ៣៧ឆ្នាំ ក្រោយពេលប្រព្រឹត្តបទល្មើស បានទទួលស្គាល់កំហុសរបស់ខ្លួនហើយក៏បានទៅសម្រុះសម្រួលជាមួយដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់មានការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៀតផង ដែលនេះបង្ហាញពីចេតនាក្នុងការទទួលខុសត្រូវនូវអំពើដែលខ្លួនប្រព្រឹត្ត។ ហេតុដូច្នេះដោយសារតែកាលៈ ទេសៈ នៃបទល្មើស ឬបុគ្គលិកលក្ខណ:នៃជនជាប់ចោទតម្រូវ អាចឱ្យតុលាការសម្រេចផ្តល់ស្ថានសម្រាលទោស និងសម្រេចអំពីការព្យួរទោសមួយផ្នែកដល់ជនជាប់ចោទឈ្មោះ [redacted] **វិរាជ្យ** និងឈ្មោះ [redacted] **ធឿន** ស្របទៅតាមបញ្ញត្តិមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **យាវម៉ី** បានដកពាក្យបណ្តឹង កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ពីជនជាប់ចោទឈ្មោះ [redacted] **ធឿន** និងឈ្មោះ [redacted] **វិរាជ្យ** ដោយខ្លួនបានធ្វើការដោះស្រាយជាមួយគ្នារួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីពុំទាមទារអ្វីទៀតទេ។ គប្បីតុលាការមិនយកចំណុចស្តីពីការទាមទារក្នុងបណ្តឹងនិងការទាមទារសំណងជម្ងឺចិត្តមកពិចារណាទៀតនោះឡើយ។



Scanned with CamScanner

## <u>ហេតុដូច្នេះសម្រេច</u>

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

១.ឈ្មោះ [redacted]វិរាជ្យ ភេទប្រុស អាយុ ៤៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់។

២.ឈ្មោះ [redacted]ធឿន ភេទប្រុស អាយុ ៣៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរធម្មតាទាំងអស់ ។

ពីបទ៖ **អបោក** ប្រព្រឹត្តនៅ ភូមិពពែលើ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីអំឡុងខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០១៨ តាមមាត្រា៣៧៧ និងមាត្រា៣៧៨ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

**២**-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៖ **៥៥៣** ដកបច/១៩ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វិរាជ្យ និងឈ្មោះ [redacted]ធឿន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]យាវម៉ី និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមសាលក្រមដើម

ថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]